**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ELECTRICITE DU CAMBODGE

**អគ្គិសនីកម្ពុជា**
**គណៈកម្មាធិការលទ្ធកម្ម**
លេខៈ ៣១៤៣ PC.អក

# សេចក្តីជូនដំណឹង (លើកទី២)
## ស្តីពី

សេវាកម្មដឹកជញ្ជូន តម្លើង ប្រមូលប្រាក់សងរំលស់ និងថែទាំប្រព័ន្ធ SHS-80WP ចំនួន 5,000 ប្រព័ន្ធ, ប្រព័ន្ធ SHS-325WP និងផ្ទាំងជាំបាយអគ្គិសនី៤លីត្រ ចំនួន 1,000 ប្រព័ន្ធ, និងសេវាដឹកជញ្ជូន តម្លើងប្រព័ន្ធ SHS-10WP ចំនួន 2,000 ប្រព័ន្ធ សម្រាប់ឆ្នាំ២០១៩

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តា ក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា អោយបានជ្រាបថា អគ្គិសនីកម្ពុជានឹងដាក់អោយដេញថ្លៃជាសាធារណៈដើម្បីសេវាកម្មដឹកជញ្ជូន តម្លើង ប្រមូលប្រាក់សងរំលស់ និងថែទាំប្រព័ន្ធ SHS-80WP ចំនួន 5,000 ប្រព័ន្ធ, ប្រព័ន្ធ SHS-325WP និងផ្ទាំងជាំបាយអគ្គិសនី៤លីត្រ ចំនួន 1,000 ប្រព័ន្ធ, និងសេវាដឹកជញ្ជូន តម្លើងប្រព័ន្ធ SHS-10WP ចំនួន 2,000 ប្រព័ន្ធ សម្រាប់ឆ្នាំ២០១៩។

អគ្គិសនីកម្ពុជា បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មអគ្គិសនីកម្ពុជា ដែលមានអាសយដ្ឋានៈ អាគារលេខ២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញចាប់ពី ថ្ងៃទី 05 ខែ កក្កដា ឆ្នាំ 2019 តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ៖ 023 67 66 007 និង Website : www.edc.com.kh ) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង 14:00 ថ្ងៃទី 24 ខែ កក្កដា ឆ្នាំ 2019 ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋាន ខាងលើវេលាម៉ោង 16:30 ថ្ងៃទី 24 ខែ កក្កដា ឆ្នាំ 2019 ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃ ច័ន្ទ ១៤ រោច ខែ អាសាឍ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៩
**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

ថៃ៊ត_សុខន

ចម្លងជូនៈ
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ